# សំណួរដែលត្រូវបានគេសួរជាញឹកញាប់អំពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់

សំណួរដែលត្រូវបានគេសួរជាញឹកញាប់អំពីការពិនិត្យ
របាយការណ៍ជាសកលតាមកាលកំណត់




រូបថត អ.ស.ប/Jean-Marc Ferré

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

សំណួរសួរ
ជាញឹកញាប់

របាយការណ៍ជាសកលតាមកាលកំណត់

### តើការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់គឺជាអ្វី?

ការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR) គឺជាដំណើរការតែមួយគត់ដែលពាក់ព័ន្ធទៅនឹងការពិនិត្យតាមកាលកំណត់នូវកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកអង្គការសហប្រជាជាតិទាំង១៩៣រដ្ឋ។ UPR គឺជានវានុវត្តន៍ដ៏សំខាន់មួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ឈរលើគោលការណ៍ស្មើគ្នាសម្រាប់ប្រទេសទាំងអស់។ ដំណើរការនេះ ផ្តល់ឱកាសដល់រដ្ឋទាំងអស់ក្នុងការប្រកាសពីវិធានការទាំងឡាយដែលរដ្ឋបានចាត់ឡើង ដើម្បីលើកស្ទួយស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន និងដើម្បីជំនះបញ្ហាប្រឈមដើម្បីសម្រេចបានសិទ្ធិមនុស្ស។ UPR រួមបញ្ចូលផងដែរនូវការចែករំលែកការអនុវត្តល្អបំផុតខាងសិទ្ធិមនុស្សនៅលើពិភពលោក។

### តើ UPR ត្រូវបានបង្កើតឡើងយ៉ាងដូចម្ដេច?

UPR ត្រូវបានបង្កើតឡើង នៅពេលដែលក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ដោយមហាសន្និបាត អ.ស.ប ក្នុងសេចក្តីសម្រេចចិត្តលេខ ៦០/២៥១។ សេចក្តីសម្រេចចិត្តនេះ បានតម្រូវឲ្យក្រុមប្រឹក្សា "ទទួលរ៉ាប់រងពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ដោយផ្អែកលើព័ត៌មានដែលអាចទុកចិត្តបាន និងជាក់លាក់អំពីការបំពេញដោយរដ្ឋនីមួយៗនូវកាតព្វកិច្ច និងការប្តេជ្ញាចិត្តសិទ្ធិមនុស្សរបស់ខ្លួន តាមរបៀបមួយដែលធានាសកលភាពនៃការគ្រប់ដណ្តប់ និងការប្រព្រឹត្តដោយស្មើគ្នាចំពោះរដ្ឋទាំងអស់"។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ រយៈមួយឆ្នាំបន្ទាប់ពីកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាថ្មីនេះបានអនុម័តយល់ព្រមឲ្យមានកញ្ចប់កសាងស្ថាប័ន (A/HRC/RES/5/1) របស់ខ្លួន ដែលផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់ការងារនៅថ្ងៃខាងមុខរបស់ក្រុមប្រឹក្សា។ ធាតុផ្សំមួយក្នុងចំណោមធាតុផ្សំគន្លឹះៗនៃកញ្ចប់នេះ គឺការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។

### តើ UPR មានគោលដៅអ្វីខ្លះ?

គោលដៅចុងក្រោយរបស់ UPR គឺការធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសនីមួយៗ។ UPR ត្រូវបានបង្កើតឡើង ដើម្បីជម្រុញ គាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅនឹងកន្លែង។ ដើម្បីសម្រេចគោលដៅនេះ UPR ធ្វើការវាយតំលៃលើរបាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋទាំងឡាយ និងដោះស្រាយការរំលោភសិទ្ធិមនុស្ស នៅគ្រប់ទិសទីដែលបញ្ហានេះកើតមាន។ UPR មានគោលបំណងផងដែរ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋនានា និងលើកកម្ពស់សមត្ថភាពរបស់ពួកគេ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈមខាងសិទ្ធិមនុស្ស និងដើម្បីចែករំលែកការអនុវត្តល្អៗក្នុងវិស័យសិទ្ធិមនុស្ស។

### តើរបាយការណ៍កម្ពុជាត្រូវបានពិនិត្យចុងក្រោយនៅពេលណា?

កម្ពុជាត្រូវបានពិនិត្យនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤។ ក្នុងអំឡុងពេលសន្ទនាអន្តរកម្ម គណៈប្រតិភូមកពី ៧៦រដ្ឋបានធ្វើសេចក្តីថ្លែងការណ៍។ កម្ពុជាទទួលយកអនុសាសន៍១៦៣ បានកត់សម្គាល់៣៨ ហើយបានច្រានចោលអនុសាសន៍៤។

### តើការពិនិត្យបន្ទាប់នឹងត្រូវធ្វើឡើងនៅពេលណា?

កម្ពុជានឹងត្រូវបានធ្វើការពិនិត្យនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចាប់ពីម៉ោង២០:៣០ ដល់ពាក់កណ្តាលអាធ្រាត្រ (ម៉ោងនៅកម្ពុជា)។

សំណួរសួរ ជាញឹកញាប់

របាយការណ៍ជាសកលតាមកាលកំណត់

### តើអ្នកណានឹងធ្វើការពិនិត្យនេះ?

ការពិនិត្យនេះ នឹងត្រូវធ្វើឡើងដោយក្រុមការងារ UPR ដែលមានសមាជិកចំនួន ៤៧ រូប នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋសមាជិកណាមួយរបស់ អ.ស.ប អាចចូលរួមក្នុងកិច្ចសន្ទនានេះបាន។ ការពិនិត្យរបាយការណ៍របស់រដ្ឋនីមួយៗត្រូវបានជួយឧបត្ថម្ភដោយក្រុមនៃរដ្ឋបី ដែលត្រូវបានគេស្គាល់ថាជា "ត្រយកាស៍" ដែលមានតួនាទីជាអ្នករាយការណ៍។ ការជ្រើសរើសត្រយកាស៍សម្រាប់រដ្ឋនីមួយៗត្រូវបានធ្វើឡើងតាមរយៈការចាប់ឆ្នោតបន្ទាប់ពីការបោះឆ្នោតសម្រាប់ការចូលជាសមាជិកក្រុមប្រឹក្សានៅក្នុងមហាសន្និបាត។

### តើការពិនិត្យត្រូវផ្អែកលើអ្វីខ្លះ?

ការពិនិត្យនេះនឹងត្រូវផ្អែកលើឯកសារចំនួនបីគឺ៖

១. របាយការណ៍ជាតិ៖ ព័ត៌មានដែលរដ្ឋស្ថិតក្រោមការពិនិត្យបានផ្តល់ឲ្យ។

២. ការចងក្រងព័ត៌មានរបស់ អ.ស.ប ៖ ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់ក្រុម ឬអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យដែលគេស្គាល់ថាជានីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងអង្គភាពអង្គការសហប្រជាជាតិផ្សេងៗទៀត។

៣. របាយការណ៍ភាគីពាក់ព័ន្ធដទៃទៀត៖ ព័ត៌មានពីអ្នកពាក់ព័ន្ធដទៃទៀត រួមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា។

### តើការពិនិត្យនឹងត្រូវបានធ្វើឡើងដោយរបៀបណា?

ការពិនិត្យនេះនឹងធ្វើឡើងតាមរយៈកិច្ចពិភាក្សាអន្តរកម្មរវាងកម្ពុជានិងរដ្ឋសមាជិក អ.ស.ប ដទៃទៀត។ កិច្ចពិភាក្សានេះធ្វើឡើងក្នុងអំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ UPR ។ ក្នុងអំឡុងពេលពិភាក្សានេះ រដ្ឋសមា ជិក អ.ស.ប អាចសួរសំណួរ ផ្តល់មតិ និង/ឬផ្តល់អនុសាសន៍ដល់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។ ត្រយកាស៍អាចដាក់សំណួរ ឬបញ្ហាជាក្រុម ដើម្បីចែករំលែកជាមួយរដ្ឋដែលស្ថិតក្រោមការពិនិត្យ ដើម្បីធានាថាកិច្ចសន្ទ នាអន្តរកម្មធ្វើឡើងដោយរលូន និងមានសណ្តាប់ធ្នាប់។ ការពិនិត្យនេះមានរយៈពេល៣ម៉ោង និង ៣០នាទី។

### តើអង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមក្នុងដំណើរការ UPR បានឬទេ?

បាន។ អង្គការមិនមែនរដ្ឋាភិបាលបានបញ្ជូនព័ត៌មានដែលត្រូវបានបន្ថែមទៅរបាយការណ៍ "អ្នកពាក់ព័ន្ធផ្សេងទៀត" ។ ព័ត៌មានដែលពួកគេបានផ្តល់ អាចត្រូវបានបញ្ជូនទៅដោយរដ្ឋណាមួយ ដែលចូលរួមក្នុងកិច្ចពិភាក្សាអន្តរកម្ម ក្នុងអំឡុងពេលពិនិត្យនៅក្នុងកិច្ចប្រជុំក្រុមការងារ។ អង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមក្នុងសម័យប្រជុំរបស់ក្រុមការងារ UPR និងអាចធ្វើសេចក្តីថ្លែងការណ៍នាសម័យប្រជុំទៀងទាត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅពេលលទ្ធផលនៃការពិនិត្យរបស់រដ្ឋត្រូវបានយកមកពិចារណា។

### តើកាតព្វកិច្ចសិទ្ធិមនុស្សអ្វីខ្លះ ដែលត្រូវបានលើកយកមកពិភាក្សា?

UPR នឹងវាយតម្លៃពីវិសាលភាពដែលកម្ពុជាគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ដូចមានចែងក្នុង៖

១. ធម្មនុញ្ញអង្គការសហប្រជាជាតិ

២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

៣. សន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលកម្ពុជាបានផ្តល់សច្ចាប័ន។

៤. ការសន្យានិងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់កម្ពុជា និង

៥. ច្បាប់មនុស្សធម៌អន្តរជាតិដែលស្ថិតនៅជាធរមាន។

សំណួរសួរ
ជាញឹកញាប់

របាយការណ៍ជាសកលតាមកាលកំណត់

## តើលទ្ធផលនៃការពិនិត្យនេះ មានអ្វីខ្លះ?

បន្ទាប់ពីការពិនិត្យនេះ របាយការណ៍មួយហៅថា "របាយការណ៍លទ្ធផល" ត្រូវបានរៀបចំដោយត្រយកាស៍ ដោយមានការជួយឧបត្ថម្ភពីការិយាល័យ OHCHR ។ របាយការណ៍លទ្ធផលនេះ សង្ខេបការពិភាក្សាក្នុងអំឡុងពេលនៃការពិនិត្យ អនុសាសន៍នានាសម្រាប់កម្ពុជា និងការឆ្លើយតបរបស់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា មានជំរើសក្នុងការទទួលយក ឬបដិសេធអនុសាសន៍ណាមួយដែលបានមកពីការពិនិត្យនេះ ហើយត្រូវជូនដំណឹងទៅត្រយកាស៍អំពីការសម្រេចចិត្តរបស់ខ្លួនចំពោះការដាក់បញ្ចូលក្នុងរបាយការណ៍លទ្ធផល។ របាយការណ៍លទ្ធផល ត្រូវបានអនុម័តដំបូងគេដោយក្រុមការងារ ហើយបន្ទាប់មកត្រូវបានអនុម័តនាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងខែមិថុនា ឆ្នាំ២០១៩។

## តើការពិនិត្យនេះ ត្រូវបានអនុម័តដោយរបៀបណា?

ក្នុងអំឡុងពេលនៃសម័យប្រជុំក្រុមការងាររយៈពេលកន្លះម៉ោង ត្រូវបានកំណត់ដើម្បីអនុម័តរបាយការណ៍លទ្ធផលនីមួយៗសម្រាប់រដ្ឋទាំងអស់ដែលបានពិនិត្យនាសម័យប្រជុំនេះ។ ការធ្វើបែបនេះ កើតឡើងមិនឆាប់ ជាង ៤៨ ម៉ោងក្រោយពីការពិនិត្យរបស់ប្រទេស។ កម្ពុជានឹងមានឱកាសធ្វើសេចក្តីអត្ថាធិប្បាយបឋមលើអនុសាសន៍ដែលត្រូវជ្រើសរើស ដើម្បីទទួលយក ឬកត់សម្គាល់។ ទាំងអនុសាសន៍ដែលបានទទួលយក ទាំងអនុសាសន៍ដែលបានកត់សម្គាល់ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍។ បន្ទាប់ពីរបាយការណ៍ត្រូវបានអនុម័ត ការកែប្រែកែសម្រួលអាចត្រូវបានធ្វើឡើងចំពោះរបាយការណ៍របស់រដ្ឋ ទៅលើសេចក្តីថ្លែងរបស់រដ្ឋនោះផ្ទាល់ នៅក្នុងរយៈពេលពីរសប្តាហ៍ក្រោយ។ របាយការណ៍នេះ នឹងត្រូវអនុម័តនាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៅខែមិថុនា ឆ្នាំ២០១៩។ នៅក្នុងអំឡុងពេលនៃសម័យប្រជុំពេញអង្គ កម្ពុជានឹងអាចឆ្លើយតបទៅនឹងសំណួរ និងបញ្ហានានាដែលមិនទាន់ត្រូវបានដោះស្រាយគ្រប់គ្រាន់ ក្នុងអំឡុងពេលនៃក្រុមការងារ និងឆ្លើយតបទៅនឹងអនុសាសន៍ ដែលត្រូវបានលើកឡើងដោយរដ្ឋទាំងឡាយនៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍។ មានការកំណត់ម៉ោងផងដែរដល់រដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍ ដែលមានបំណងបញ្ចេញមតិរបស់ខ្លួន លើលទ្ធផលនៃការពិនិត្យ និងសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើអត្ថាធិប្បាយទូទៅ។

## តើជំហានបន្ទាប់អ្វីខ្លះ ដែលត្រូវធ្វើ ដើម្បីអនុវត្តន៍តាមការត្រួតពិនិត្យ?

រាជរដ្ឋាភិបាលកម្ពុជា មានការទទួលខុសត្រូវចម្បង ក្នុងការអនុវត្តអនុសាសន៍ដែលមាននៅក្នុងលទ្ធផលចុងក្រោយ។ UPR ធានាថា ប្រទេសទាំងអស់ត្រូវទទួលខុសត្រូវចំពោះវឌ្ឍនភាព ឬភាពបរាជ័យក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ នៅក្នុងការពិនិត្យមើលជុំទីបីនេះ ប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងផ្តល់ព័ត៌មានអំពីកិច្ចការដែលខ្លួនបានធ្វើ ដើម្បីអនុវត្តអនុសាសន៍ដែលបានធ្វើឡើង ក្នុងអំឡុងពេលពិនិត្យកន្លងមក ក៏ដូចជាលើការវិវត្តន៍ណាមួយនៅក្នុងវិស័យសិទ្ធិមនុស្ស។

សហគមន៍អន្តរជាតិអាចជួយក្នុងការអនុវត្តអនុសាសន៍ និងសេចក្តីសន្និដ្ឋាននានាទាក់ទងនឹងការកសាងសមត្ថភាព និងជំនួយផ្នែកបច្ចេកទេស ដោយធ្វើការពិគ្រោះយោបល់ជាមួយប្រទេសសាមី។